**ខ្លឹមសារសង្ខេប**

**សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ១៣ ខែធ្នូ ឆ្នាំ២០១១** [( E138/1/7)]

**ពាក្យគន្លឹះ៖** សិទ្ធិទទួលបានសវនាការដោយគ្មានបង្អង់យូរ, ភាពសមស្របក្នុងការដាក់ក្រោមសវនាការ (unfit to stand for trial), យុត្តិសាស្ត្រអន្តរជាតិ, តួនាទីរបស់ TC និង CoP, ភាពខុសគ្នារវាងផ្អាកនិងបញ្ចប់នីតិវិធី

## ១. ប្រវត្តិនីតិវិធីនិងខ្លឹមសារសម្រេច

**ក.** ក្នុងអំឡុងពេលនៃនីតិវិធីជំនុំជម្រះសំណុំរឿង០០២ សុខភាពផ្លូវចិត្តរបស់ អៀង ធីរិទ្ធ (**អធរ**) មានបញ្ហា (កើតជំងឺវង្វេងវង្វាន់) ដែលនាំឲ្យមានចំណោទមួយសួរថា គាត់អាចចូលរួមការពារខ្លួនក្នុងសវនាការមានប្រសិទ្ធភាពដែរឬទេ? អង្គជំនុំជម្រះសាលាដំបូង (TC) បានពិចារណាលើញត្តិឲ្យផ្អាកនីតិវិធីសវនាការលើ **អធរ** និងសម្រេចផ្អាកនីតិវិធី ដោះលែងដោយគ្មានដាក់លក្ខខណ្ឌ (រកសំឡេងភាគច្រើន៤សំឡេងមិនបាន) ផ្អែកលើមូលដ្ឋានមួយចំនួនដូចជា ការរាំងស្ទះដល់សវនាការនៃជនជាប់ចោទដទៃទៀត និង**អធរ** មិនអាចអនុវត្តសិទ្ធិចម្បងក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌។ ចៅក្រមកម្ពុជា (ភាគច្រើន) អះអាងថា មាត្រា២២៣(១១) ស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ អនុវត្តបាន ក៏ប៉ុន្តែ ចៅក្រមអន្តរជាតិអះអាងថា មិនអនុវត្តបានទេ។ ក្រោយពីរកសំឡេងមិនបាន គឺត្រូវសម្រេចល្អៀងទៅរកជនជាប់ចោទ នោះគឺដោះលែងឲ្យមានសេរីភាព ([E138])។

> *អវត្តមាននៃការព្រមព្រៀង អំពីលក្ខខណ្ឌចំពោះការដោះលែង គឺនាំឲ្យស្ថានភាពរបស់ជនជាប់ចោទមានភាពមិនច្បាស់លាស់។ ជាលទ្ធផលនៃសេចក្តីសម្រេចនេះ ប្រសិនបើមាន ប្រសិនបើជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានរក្សាទុកនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ឬត្រូវដាក់ឲ្យព្យាបាលដោយបង្ខំនៅមន្ទីរពេទ្យ លទ្ធភាពដែលអាចកើតមាននោះ គឺជាការបន្តឃុំឃាំងមិនមានមូលដ្ឋានច្បាប់ទេ។ ដើម្បីកុំឲ្យមានបញ្ហានេះ អង្គជំនុំជម្រះយល់ស្របគ្នាជាឯកច្ឆ័ន្ទថា ដំណោះស្រាយតែមួយគត់នៅក្នុងស្ថានភាពនេះ គឺត្រូវដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ។*

**ខ.** សហព្រះរាជអាជ្ញា (CoP) <u>បានប្តឹងសាទុក្ខបន្ទាន់ </u>ទៅអង្គជំនុំជម្រះតុលាការកំពូល (SC) ឲ្យផ្អាកដោះលែងសិន រង់ចាំសេចក្តីសម្រេចរបស់តុលាការកំពូលនេះ។ CoP បានអះអាងថា TC ធ្វើខុស

ដោយបំពានច្បាប់ ដោះលែងដោយគ្មានដាក់លក្ខខណ្ឌ។ វិធាន៨២(១) ជនជាប់ចោទត្រូវនៅក្នុងមន្ទីរឃុំឃាំង រហូតដល់មានសេចក្តីសម្រេច...ការដោះលែងនេះ ប៉ះដល់ប្រយោជន៍ជនរងគ្រោះ និងបំណងសហគមន៍អន្តរជាតិចង់ឃើញការវិនិច្ឆ័យសេចក្តី (កថា១១) (E138/1/1)។ មេធាវីរបស់ **អធរ** បានអះ អាងថា ការផ្អាកជាការត្រឹមត្រូវដោយសារ គ្មានការរំពឹងថា សវនាការកើតមាន ដោយសារសុខភាព **អធរ** នឹងមិនប្រសើរ ទេ (E138/1/5)។

**គ.** ជាដំបូង SC ត្រូវពិចារណាថា តើបណ្តឹងរបស់ CoP អាចទទួលយកបាន។ SC ទំនងយល់ស្របតាម CoP បកស្រាយវិធាន១០៤(៤.កនិងខ) ដែលថា ការដោះលែងនៅក្រៅឃុំដោយគ្មានដាក់លក្ខខណ្ឌ នាំឲ្យ អវតក គ្មានសិទ្ធិក្នុងការចាត់វិធានការណាមួយ មានន័យថា ជាការបញ្ចប់នីតិវិធីជាអចិន្ត្រៃយ៍ ដែលសេចក្តីសម្រេចនេះ អាចប្តឹងសាទុក្ខបាន។

**ឃ. SC** បានពិនិត្យមើលបទប្បញ្ញត្តិច្បាប់កម្ពុជានិងអះអាងថា អាចផ្អាកនីតិវិធីករណីបណ្តឹងបន្ទាន់បង្ខំ ឬកម្មវត្ថុបណ្តឹងស្ថិតនៅក្នុងសមត្ថកិច្ចតុលាការផ្សេង..។ ដូចនេះ ច្បាប់កម្ពុជាមិនមានចែងអំពីការផ្អាកដោយសារ ភាពមិនសមស្របក្នុងការដាក់ក្រោមសវនាការទេ (unfit to stand for trial)។ SC អនុលោមតាមច្បាប់ ពិនិត្យមើលយុត្តិសាស្រ្តនិងការអនុវត្តបរទេស ហើយរកឃើញថា ការដោះលែងដោយគ្មានដាក់លក្ខខណ្ឌ ជាករណីពិសេស។ ក្នុងសំណុំរឿង *Djukic* ជនជាប់ចោទ មានជំងឺមិនអាចព្យាបាលបាន ក៏តុលាការដោះលែងដោយដាក់លក្ខខណ្ឌនិងបញ្ចប់នីតិវិធីក្រោយពេលស្លាប់។ ការអនុវត្តបង្ហាញថា មិនបញ្ចប់នីតិវិធីទេ តុលាការនឹងវាយតម្លៃឡើងវិញ ប្រសិនជនជាប់ចោទ អាចចូលរួមសវនាការបាន សេចក្តីសម្រេចត្រូវបាន Reversed។

អនុលោមតាមនេះ **SC** ទទួលយកនូវបណ្តឹងសាទុក្ខ និងបដិសេធដីកាដោះលែងដោយគ្មានដាក់លក្ខខណ្ឌ ស្នើឲ្យមានការព្យាបាល **អធរ** ក្នុងមន្ទីរពេទ្យ...បញ្ជាឲ្យមានការពិនិត្យសុខភាព **អធរ** និងបង្គាប់ឲ្យ TC ធ្វើកិច្ចការងារនេះ។

## ២. កំណត់សំគាល់

**ក.** ក្នុងសេចក្តីសម្រេចនេះ មានការកំណត់សមត្ថកិច្ចរវាង CoP និង TC។ ខណៈ ដែលអះអាងថាជាសមត្ថកិច្ចរបស់ CoP តុលាការកំពូល អះអាងថា រឿងនេះស្ថិតនៅក្នុងដៃរបស់ TC ដូចនេះ TC ត្រូវទទួលខុសត្រូវលើការឃុំខ្លួន **អធរ**។ **ខ.** យុត្តិសាស្រ្តបង្ហាញថា ការសម្រេចដោះលែងដាក់ឬគ្មានដាក់លក្ខខណ្ឌ ត្រូវតែបានពិចារណាគ្រប់ជ្រុងជ្រោយ ផលប្រយោជន៍ភាគីពាក់ព័ន្ធ។